# កម្លាំង និង ទុព្វលភាព ខ្មែរ

## La force et la faiblesse khmère

សរសេរ ដោយ ឧប សៅ សង្ហា

២៥ ធ្នូ ឆ្នាំ ២០១៤



# មាតិការឿង

**សេចក្តីផ្តើម**

- ការគោរពជំនឿ «មេ-ប៉ា»

**១. ការចេះដឹង បុរាណខ្មែរ ឬ មូលដ្ឋាន បញ្ញាខ្មែរ**

**២. ដំណើរ នៃ ការចេះដឹងខ្មែរ**

# សេចក្តីផ្តើម

ស្រុកខ្មែរ ជា ប្រជាជាតិ មាន អាយុ ជា ច្រើនសហស្សវត្ស នៅក្នុង ដំបន់ អាស៊ី អគ្នេយ៍ បណ្តា ប្រជាជាតិ ដទៃទៀត គឺ មន និង ចំប៉ា។ ប្រជាជន ខ្មែរ ក្នុង បុព្វប្រវត្តិសាស្ត្រ មាន **ការគោរពជំនឿ**[1] «**មេ-ប៉ា**» ឬ «**ម៉ែ-ឪ**» គឺជា ជំនឿ គោរព «**បុព្វជន**» ឬ «**ចាស់បុរាណ**» មុន ខ្លួន បាន ជួបប្រទះនឹង ជំនឿថ្មី គឺ ព្រហ្មញ្ញសាសនា និង ពុទ្ធសាសនា មហាយាន។

គួរលើកយក ការគោរពជំនឿ «មេ-ប៉ា» មក អធិប្បាយ តាម ការត្រិះរិះ[2] ផ្ទាល់ខ្លួន របស់ ករី កេង-វ៉ាន់សាក់ ព្រោះ ថា ទស្សនៈ ជំនឿ ដើម ខ្មែរ នេះ តាម វិស័យ ទស្សនៈវិជ្ជា មាន តិចតួច បំផុត នៅក្នុង ការសិក្សា ខ្មែរ ក្រៅតែ ពី ការសិក្សា អំពី ជំនឿ លើ «**អ្នកតា**»។ ក្នុង ចំណុចនេះ យើង យល់ឃើញ ថា មាន តែ ករី កេង-វ៉ាន់សាក់, លោក សាកល្បង យក ការគោរពជំនឿ «មេ-ប៉ា» ជា គំនិតផ្តើម មក បង្កើត ជា សំណើ មួយ សំរាប់ ខ្មែរយើង យកវា ទៅពិចារណា បន្ថែម តាម ការយល់ឃើញ រៀងៗខ្លួន។ សំណើ នេះ មិនទុក ជា **ស្វ័យស័ត្យ**[3] នោះឡើយ ដែលនាំឲយើង យកវាមក បំបែង ជា **បទតទ្ធិត**[4] ដោយ ប្រើ ភាសា សម័យ និង គំនិត «**ការចាត់ការ**[5]» ដើម្បី ស្រួលងាយយល់ អំពី ដួង ទស្សនៈ នេះ។

## ការគោរពជំនឿ «មេ-ប៉ា»

**មេ** មានន័យ ច្រើន នៅក្នុង ការត្រិះរិះ ខ្មែរ៖ ជា **ម្តាយ** ជា **ភាពឧត្តុងឧត្តម** ជា**គតិ**[6] ជា**ប្រភព**។

**ប៉ា** មានន័យ ជា **ឪពុក** ជា **អ្នកការពារ** ជា **មាគ៌ា** ជា **គតិបណ្ឌិត**។ នៅក្នុង ពាក្យ ប៉ា នោះដែរ មាន ទស្សនៈ បី យ៉ាង៖ **ព្រះ ចៅ** និង **តា**។ នៅក្នុង វប្បធម៌ ខ្មែរបុរាណ ពាក្យ «ព្រះ» មាន ន័យ ជា «មាគ៌ា ឬ គោលដៅ», ពាក្យ «ចៅ» មាន ន័យ ជា «អ្នកការពារ» រីឯពាក្យ «តា» មាន ន័យ ជា «បុព្វបុរស ឬ គតិបណ្ឌិត»។

នៅក្នុង ការគោរពជំនឿ «មេ-ប៉ា» យើង ឃើញ ថា សង្គម បុរាណ ខ្មែរ ជា សង្គម **មតេយ្យការ**[7] ទុក ស្ត្រី ជា សព្វ ប្រភព នៃ ជីវិត រស់នៅ ក្នុង សង្គម ដូច្នេះ ជា ឧត្តមមនុស្សលោក ដែលត្រូវតែ គោរព។ បើ ស្ត្រី ក្លាយ ជា មាតា គឺ ជា គតិ ព្រោះ លោក ជា អ្នក បីបាច់ ថែទាំរក្សា ប្រកប ដោយ សេចក្តី ស្នេហា ចេញពី ដួងចិត្តា ដ៏ បរិសុទ្ធ ពី វ័យ ទារក ដល់ ពេញវ័យ ឲ ស្គាល់ បទដ្ឋាន នូវ អ្វី ដែល ជា អំពើ ល្អ អំពើ អាក្រក់ ក្នុង ការរស់នៅ ជា ប្រក្រតិ។ ការគោរព មាតា ជា សាលារៀន

[1] ការគោរពជំនឿ=Culte។
[2] ការត្រិះរិះ= La pensée។
[3] ស្វ័យស័ត្យ= សំណើ ទុកជា ការពិត ជាក់ស្តែង (Axiome)។
[4] បទតទ្ធិត= ដែលក្លាយមក ពី វចនៈ វត្ថុ ឬ គំនិត ដទៃ (Dérivé)
[5] ការចាត់ការ= Management។
[6] គតិ=l’esprit។
[7] មតេយ្យការ=ទុកស្ត្រី ជា ភាពឧត្តុងឧត្តម (Matriarcat)។

នូវ សេចក្ដីត្រាប្រណី សេចក្ដីស្នេហា បរិសុទ្ធ ដែល ជា គតិ នៃ មនុស្សជាតិ។ មនុស្សលោក កើត មក នាំមក នូវ សេចក្ដីស្នេហា រវាង មាតា នឹង ខ្លួន ដែលមាននៅក្នុងច្បាប់ ធម្មជាតិ ដែល ជា ច្បាប់ ទី១ នៃ មនុស្សជាតិ។

ដើម្បី រៀបចំ សង្គម ឲមាន លំដាប់ លំដោយ ត្រូវការ ចាំបាច់ មាន អ្នកនាំផ្លូវ ប្រកបដោយ គតិបណ្ឌិត មាន គ្រោងគំនិត ជា លំដាប់ ដែល ទុក ជា «មាគ៌ា» សំរាប់ ដើរ សំដៅ ទៅរក ទី ដៅ។ ការកសាង មាគ៌ា នេះ ជា កិច្ចការ របស់ «ប៉ា»។ ប៉ា មាន ធាតុ បី ដែល យើង បាន លើក មក បង្ហាញ រួចមកហើយ គឺៈ

ទី១. គឺ «**ព្រះ**»៖ ជា គោលបំណង កសាង សង្គម មាន លំដាប់លំដោយ មាន វិន័យ ជា ការដឹកនាំ មាន សីលធម៌ ជា បទដ្ឋាន នៃ យុត្តិធម៌ មាន គោលដៅ ច្បាស់លាស់ ហើយ ត្រូវចាំបាច់ ធ្វើឲ សម្រេចបាន ដើម្បី សេចក្ដីចំរើន នៃ មនុស្សជាតិ។

ទី២. គឺ «**ចៅ**»៖ ជា អ្នកដឹកនាំ កម្មវិធី នៃ គោលបំណង ដែល ជាបុគ្គល មាន គុណសម្បត្តិ ជា អ្នកប្រមែប្រមូល ជាទី ស្រឡាញ់ នូវ សមាជិក សង្គម ឲមក ជ្រក កាយា ក្រោម ឆាយា ឆ័ត្រ ប្រកប ដោយ សេចក្ដីស្នេហា សំរាប់ការពារ និង ឧបត្ថម្ភ រួមរស់ ក្នុង សេចក្ដីសុខ ដែលនាំ ឲមាន **សិនិទ្ធពល**[8] ក្នុងសង្គម ដើម្បី ជ្រោមជ្រែង កសាង **សម្មាសង្គម**[9]។

ទី៣. គឺ «**តា**»៖ សាស្ត្រា ឬ សតិ នៃ ការចេះដឹង របស់ បុព្វបុរស ដែល លោក ចងក្រងទុក ជា ក្បួន ច្បាស់លាស់ សំរាប់ ការរស់នៅ របស់ សមាជិក សង្គម ដើម្បី ឲមាន សុខដុម។ ក៏ជា ប្រជុំ វិជ្ជា សំរាប់ រក សេចក្ដីពន្យល់ ដើម្បី ស្វែង រក ដំណោះស្រាយ ចំពោះមុខ វិបត្តិ ណាមួយ ដែល សង្គម ជួបប្រទះ។ ដូច្នេះ «តា» ជា ប្រភព នៃ ការចេះដឹង សកម្ម មាន លក្ខណៈ ជា ប្រភព ជា ថាមវន្ត ព្រោះ អ្វី ដែល បាន ធ្វើ រួចហើយ អ្នកដឹកនាំ ពី ជំនាន់មួយ ទៅ ជំនាន់ តែងតែ ចារ ទុក ជា ក្បួនសាស្ត្រ ថ្មី សំរាប់ សមាជិក ជំនាន់ក្រោយ។

រួមសេចក្ដីមក ការគោរពជំនឿ «មេ-ប៉ា» ជា ការត្រិះរិះ ជា ថាមវន្ត មាន កម្លាំង រុញ ទៅរក អ្វី ដែល ជា សម័យ ដើម្បី យក របស់ ថ្មី ដែលបាន ជួបប្រទះ មកផ្សំ ជា គំនិត ថ្មី សំរាប់ បន្តការ រស់នៅ នៃ មនុស្សលោក ក្នុង សង្គមជាតិ។ ហេតុនេះឯង បាន ជា ខ្មែរយើង មាន លទ្ធភាព និង ទេពកោសល្យ អាច កែឆ្នៃ វប្បធម៌ តណ្ហាតាម សន្តិវិធី បាន ជា វប្បធម៌ ថ្មីមួយ ដែល គេ ឲឈ្មោះ ថា អារ្យធម៌ អង្គរ។ តើ ទេកោសល្យបែប នេះ មិនមែន ជា កម្លាំងខ្មែរ នោះ ឬទេ ?

[8] សិនិទ្ធពល= ការរួបរួម (Cohésion)។
[9] សម្មាសង្គម= Une société juste។

## ១. ការចេះដឹង បុរាណខ្មែរ ឬ មូលដ្ឋាន បញ្ញាខ្មែរ

ការ ដែល ខ្មែរយើង មាន ការភាន់ច្រឡំ គឺ យើង នាំគ្នា យក អារ្យធម៌ អង្គរ មកធ្វើ ជា គំនិត សឹក ពូកែ កាប់ចាក់ នៅក្នុង សមរភូមិ ថា ពូជខ្មែរ ជា ពូជ អ្នកចម្បាំង កសាង មហានគរ។ និយាយ សង្កត់តែ អំពី អំណាចយោធា គឺ ខ្មែរយើងនាំគ្នា ទទួលស្គាល់ នូវ ច្បាប់ នៃ ធម្មជាតិ ទទួលស្គាល់ ឯកសិទ្ធិ អ្នកខ្លាំង លើ អ្នកខ្សោយ៖ អ្នកឈ្នះ ប្រើអំណាច ឲ អ្នកចាញ់ ស្តាប់បង្គាប់ ជា ដាច់ខាត។

ទស្សនៈនេះ ដែលនាំ ឲខ្មែរយើងមិនសូវ យកចិត្តទុកដាក់ អំពី គ្រិះ ពិត របស់ ខ្លួន គឺ ការចេះ ដឹងខ្មែរ លើសពី វិស័យ យោធា ដែលជា កម្លាំងទ័ព វាយបង្ក្រាប សត្រូវ និង វាតទឹកដី ដូចមាន វិស័យ «**ធនធានមនុស្សលោក**» «**ធនធានធម្មជាតិ**»និង «**ការចាត់ចែង នៃ គតិលោក**» ដែល ជា ការចេះដឹង មូលដ្ឋាន នៃ ការរស់នៅ របស់ មនុស្សលោក។

*«**គតិលោក**៖ និយមន័យ តាម ឧញ៉ា **សុត្តន្តប្រីជាឥន្ទ**[10]៖ **លោក** ជាភាវៈដែលកើតឡើងដោយ អំណាចបដិសន្ធិនៃខន្ធ គឺថា សភាវៈមិនទៀង ដោយមិនជាប់នៅមិនប្រាកដ ជា អទស្សនភាព។ មួយទៀត ប្រែថា សត្វផែនដី ផ្ទៃមេឃអាកាសទួទៅទាំងអស់, លោក នេះ ប្រែថា ធម្មតា សត្វ ឬ របស់ ដែលប្រព្រឹត្តទៅក្នុងលោក។ ឯ **គតិ** សព្ទ នោះប្រែបានច្រើនយ៉ាង គឺ ជា ដំណើរ ទៅ គ្រឿងដល់ គ្រឿងដំណើរ បទសេចក្តីកម្លាំង អំណាចផ្លូវចិត្ត ទីពឹងក្តី អត់ធន់ចិត្ត។ កំណើត ពាក្យឯណា ហេតុណា វត្ថុណា ដែលកើតឡើង មានឡើង ក្នុងលោកនេះ ហៅថា «**គតិលោក**» ទាំងអស់»*

ការចេះដឹង បុរាណខ្មែរ ជា របៀបប្រើ បែប ទ្រឹស្តី និង បែប ប្រតិបត្តិ។ បុព្វបុរសខ្មែរ លោកមាន ជំនឿ លើ «**អត្ថិភាពនិយម**[11]»

*«អត្ថិភាពនិយម៖ មនុស្សលោក មិនមាន អត្តភាព ជាមុន ដោយសារ ខ្លួន មាន ធម្មជាតិ ជា មនុស្សលោក នោះទេ តែ ជា អាត្មាជិន[12] ទទួលខុសត្រូវ លើ អត្តភាព របស់ ខ្លួន»*

យើងឃើញថា ទស្សនៈ នេះ មាន ក្នុង ការគោរពជំនឿ «មេ-ប៉ា» ក្នុង សញ្ញាណ «ព្រះ ចៅ តា» គឺ ថា មនុស្សលោក តែងតែ រស់នៅ មាន គោលបំណង ល្អ (មានព្រះ) សំរាប់ អាត្មាឯង ដូច ឧញ៉ា **សុត្តន្តប្រីជាឥន្ទ** យកមក ធ្វើទ្រឹស្តី ចារថា ហេតុណា វត្ថុណា ដែលកើតឡើង ក្នុង លោកនេះ ហៅ ថា «គតិលោក» ព្រោះ គតិ ជា ដំណើរ ទៅ គ្រឿងដល់ គ្រឿងដំណើរ បទសេចក្តីកម្លាំង អំណាច ផ្លូវចិត្ត ទីពឹងក្តី អត់ធន់ក្តី (ចៅ)។ ទ្រឹស្តី នេះ ដែល ខ្មែរ បុរាណ យកមក ប្រព្រឹត្ត ក្នុង ការរស់ នៅ របស់ខ្លួន ដែលមាន ប្រភពច្បាស់លាស់ សំរាប់ ទុក ជា គោល ប្រព្រឹត្ត (តា)។

---

[10] ឧញ៉ា សុត្តន្តប្រីជាឥន្ទ (១៨៥៩-១៩២៤)=អ្នកប្រាជ្ញខ្មែរក្នុងវិស័យ ទស្សនវិជ្ជា។
[11] អត្ថិភាពនិយម=Existentialisme : Doctrine selon laquelle l’homme n’est pas déterminé d’avance par son essence, mais libre et responsable de son existence។
[12] អាត្មាជិន=សេរីជន (L’homme libre)។

មនុស្សលោក មាន កាយ ជា រូប ឃើញនឹងភ្នែក មាន អារម្មណ៍ ទាំងពួង ជា ត្រិះ អត្តនោម័តិ (មាននៅក្នុងគំនិត) គ្រប់គ្រាន់ អាចទុកបាន ជា អត្តភាពរូបី មាន នៅក្នុង ពន្លឺបញ្ញា ជា គំនិត ប្រកបទៅដោយវិចារណញ្ញាណ របស់ អាត្មា។ ឧទាហរណ៍៖ ឯង ធ្វើបាបគេ តើគេដែលជាមនុស្ស ដូចឯងដែរ តើគេមិនចេះឈឺចាប់នោះដែរឬទេ? ការយល់ដឹង អំពី អារម្មណ៍ «ឈឺចាប់» នេះហើយ ជា រូបី មាននៅក្នុង វិចារណញ្ញាណ មាន ការអប់រំ ឲស្គាល់ដឹងអ្វី ជា បាប (អំពើអាក្រក់) និង បុណ្យ (អំពើ ល្អ)។ បាប/បុណ្យ នៅទីនេះ មិនមែន ជា បាប/បុណ្យ ក្នុង សញ្ញាណកម្ម/ផល នោះទេ គឺ ជា ការទទួលខុសត្រូវ របស់ អាត្មាជន ចំពោះមុខ អំពើ ដែលខ្លួនបានប្រព្រឹត្ត ដែលមាន អនុភាព ភ្លាមៗ ដោយយក **បទដ្ឋាន**[13] នៃច្បាប់ ឬ វិន័យ ដែលមាននៅក្នុងសង្គម ជា លក្ខណវិនិច្ឆ័យ។

អធិប្បាយ អំពី ធនធានមនុស្សលោក ត្រូវចាំបាច់ ឆ្លើយនឹង សំណួរ ថា **អ្វី ជា មនុស្សខ្មែរ ?**

មនុស្សខ្មែរ មានកាយ មានកាយវិការ ដែលអាចឲគេសម្គាល់បាន ជាពិសេស រវាង ខ្មែរគ្នាឯង មានភាសា សំរាប់និយាយទាក់ទងគ្នា មានរបៀប **ត្រិះរិះ ជា យថាប្រភេទ**[14] និង នៅក្នុងបទដ្ឋាននៃ មនុស្សទូទៅ ក្នុងលោកិយ ដែលនាំឲ មនុស្សខ្មែរ អាចមានលទ្ធភាព អាចមាន ការវិវឌ្ឍន៍ តាមចរន្ត នៃសេចក្តីចំរើន នៃ មនុស្សជាតិ និង ពង្រឹង លក្ខណៈ ជា យថាប្រភេទ របស់ខ្លួនផង។ ដូច្នេះ មនុស្សខ្មែរ ជា មនុស្សលោក ធម្មតា ដូចមនុស្សលោកឯទៀត ក្នុងលោកិយ តែ ខុសពី ជនជាតិដទៃ ព្រោះខ្លួន រួមរស់ នៅក្នុងសង្គមជាតិ មាន ប្រវត្តិសាស្ត្រផ្ទាល់ មាន ភាសាផ្ទាល់ មាន ការត្រិះរិះផ្ទាល់ ខុសពីជាតិសាសន៍ដទៃទៀត ដែល ម្នាក់ៗ គេមាន លក្ខណៈ ជា យថាប្រភេទ របស់គេរៀងៗខ្លួន។

ខ្មែរបុរាណ ជា **សេរីជន** គ្មានចរិត អាត្មានិយម ព្រោះខ្លួនរស់នៅក្នុងដំបន់មួយ ដែលមានធម្មជាតិ សម្បូរទៅដោយ ធនធានគ្រប់បែបយ៉ាង សំរាប់ចិញ្ចឹមជីវិត។ ភោគ នេះហើយ ដែលបង្កើតទឹកចិត្ត **ចែកចំណែក** ដល់ អ្នកដទៃ ដែលទុកជា ចរិកលក្ខណៈ ទី១ របស់ខ្មែរ។ ការរស់នៅ ក្នុងសភាពសម្បូរ នេះ នាំឲចិត្តខ្មែរមាន **សេចក្តីត្រាប្រណី** ព្រោះ មិនទុក អ្នកខ្សត់ ជា អ្នកដណ្តើមទ្រព្យដែលទុកជា ចរិកលក្ខណៈ ទី២ របស់ខ្មែរ។ សេចក្តីត្រប្រណី នាំបង្កើតគំនិត **សាមគ្គីភាព** ដែលទុកជា ចរិកលក្ខណៈ ទី៣ របស់ខ្មែរ។ គំនិត សាម្គីភាព នេះហើយ ដែលបង្កើតជា គំនិត **សន្តិភាព** ដែលទុកជា ចរិកលក្ខណៈ ទី៤ របស់ខ្មែរ។ កត្តា ទាំងបួន នេះឯង ដែល ចាក់ជាគ្រិះ នៃ**សង្គមខ្មែរ** ដែលទុកជា ចរិកលក្ខណៈ ទី៥ របស់ខ្មែរ។ លក្ខណៈប្រាំយ៉ាងនេះដែលជាធនធាន នៃ មនុស្សខ្មែរ។

ជនខ្មែរ **គោរពធម្មជាតិ** ព្រោះវា ជា ធនធាន អាហារណីយ សំរាប់ការរស់នៅរបស់ខ្លួន និងជាប្រភពដើម នៃការទូន្មាន សំរាប់ជីវិតរស់នៅ ព្រោះធម្មជាតិ ជាប្រភពច្បាប់មួយ នៃមនុស្សជាតិ និង ជា បច្ច័យ បានមកពី អំណាច នៃ គតិអរូប ដែលខ្មែរយើង ហៅថា «**អ្នកតា**» ដែល ជា អ្នកថែរក្សា ធនធានធម្មជាតិ។ អ្នកតា នេះ ជា និមិត្តរូប នៃ **បរិស្ថានវិទ្យា** ដូចសម័យ

[13] បទដ្ឋាន=Norme។
[14] ត្រិះរិះជាយថាប្រភេទ=ការត្រិះរិះជាពួក (Penser spécifique)។

ទំនើបសព្វថ្ងៃនេះឯង។ ធ្វើអ្វីមួយ ដែលមានទំនាក់ទំនងនឹងធម្មជាតិ ខ្មែរត្រូវចាំបាច់រៀបចំពិធីបួងសួង សូមអនុញ្ញាត ពី អ្នកតា ជាមុនសិន ទើបអាចសម្រេច នូវគោលបំណងបាន។ ខ្មែរបែកចែកធម្មជាតិ ជា បី ចំណែកៈ សត្វលោកនិយម ឧតុនិយម និង ពីជនិយម។ **សត្វលោកនិយម** គឺ មនុស្សលោក និង សត្វទាំងពួង រស់នៅក្បែរគ្នា។ **ឧតុនិយម** គឺ ជាតិដី ថ្ម ក្រួស សព្វបែបយ៉ាង ដែលខ្មែរយើងហៅថា ផែនដី ទុកជាទីអាស្រ័យនៅ របស់សត្វលោក។ **ពីជលោក** គឺ រុក្ខជាតិ តិណជាតិ ស្មៅវល្លិ ផ្សេងៗ។ វត្ថុធាតុ ទាំងបីនេះ ជា ហេតុ ធម្មជាតិ ជា ផល សំរាប់ការរស់នៅរបស់លោកិយ ដែលមាន គោលការណ៍ សំខាន់មួយ ទុកជា ទស្សនៈ គឺ **សមតា បរិស្ថាន**[15]។

គតិជនខ្មែរ ក្នុង **ការចាត់ចែង គតិលោក** គឺ ផ្អែកទៅលើ សេរីភាព ការចែកចំណែក សេចក្តីត្រាប្រណី សាមគ្គីភាព និង សន្តិភាព ដែល មាន ធម្មជាតិ ជា ជម្រងអាស្រ័យរស់នៅ ក្នុងទស្សនៈ សមតា បរិស្ថាន។ សព្វគំនិតខ្មែរបុរាណ ដែលបានរៀបរាប់មកនេះ គឺ នៅក្នុងគោលបំណងមួយគត់ គឺការធ្វើឲមាន សុខដុម ក្នុង លោកិយ ដែលជា សីលធម៌ដើមមួយ នៃ មនុស្សជាតិ។ ទោះបី ជនខ្មែរ ក្នុងសម័យបុរាណ មាន ការត្រិះរិះ ក្នុងការរស់នៅ របស់ខ្លួន លូតច្រើនទៅមុខច្រើនយ៉ាងណាក្តី តែ ខ្លួន រស់នៅ ជា **តួអង្គ**[16] នៃ ធម្មជាតិ។ ប្រព័ន្ធ នៃ ការត្រិះរិះ គឺ មានកំរិតត្រឹមតែ ការចេះសង្កេត របស់ខ្លួន លើ បាតុភូត នៃ ធម្មជាតិ តែប៉ុណ្ណោះ ហើយយកវាមកធ្វើជារបបរស់នៅ ដើម្បី រក្សាសេចក្តីសុខ ចំពោះ ច្បាប់ធម្មជាតិ ដែលជាច្បាប់មួយ មានភាពប្រក្រតីផង តែក៏វាមាន ភាពមិនទៀងទាត់ដែរ។ អ្វីដែលមិនទៀងទាត់ ខ្មែរយើង យកវាមកបកស្រាយ ជា ទណ្ឌកម្ម ដែល ធម្មជាតិ ដាក់ទោស ព្រោះខ្លួន បានធ្វើអ្វីមួយ ដែលនាំមានការខុសឆ្គងដល់ គតិនៃធម្មជាតិ ហើយចម្លើយ នូវទណ្ឌកម្មនេះ មានតែមួយគត់ គឺ ពិធីបន់ស្រន់សូមខមាទោស ពីធម្មជាតិ (អ្នកតា) មានសែនពៃ សូមឲ សព្វពិសិដ្ឋវត្ថុ លុបលាងកំហុសខ្លួន។ បើយើងយកវិធីនេះ មកធ្វើការពិចារណាបន្តិច យើងឃើញថាវា ជាគំនិតអវិជ្ជមានទាំងស្រុងនោះឡើយ ព្រោះក្នុងពិធីបន់ស្រន់សូមខមាទោសនេះ មាន គោលការណ៍សំខាន់ពីរយ៉ាងៈ ទី១ គឺការទទួលស្គាល់កំហុសរបស់ខ្លួន ទី២ សន្យាថាខ្លួនឈប់ធ្វើអំពើ ដែលនាំឲមានការខុសឆ្គងនេះទៀតហើយ ដូច្នេះបើយើងយកគោលការណ៍ទាំងពីរនេះ មក បូករួម បង្កើតបាន ជា គោលការណ៍ នៃ មេរៀន សំរាប់ការរស់នៅនេះឯង។ គំនិត បន់ស្រន់សូមខមាទោស មិនមែនជាគំនិត **កម្មវាសនាគេចមិនផុត** នោះឡើយ គំនិតសំខាន់ដែលមានក្នុងគំនិតបុរាណខ្មែរ គឺ ការទទួលកំហុស ព្រមនឹង ការជួលជុលជម្ងឺចិត្ត។ ចំណុចនេះ រឹតតែបញ្ជាក់បន្ថែមថា ជនខ្មែរ ក្នុងសម័យបុរាណ ជា ជន មានការទទួលខុសត្រូវ នូវ សព្វអំពើ ដែលខ្លួនបានប្រព្រឹត្តិ។ ការដឹងនៃការទទួលខុសត្រូវនេះឯង ដែលនាំបង្កើតឲមាន នៅក្នុងគតិខ្មែរ នូវ សញ្ញាណ គតិយុត្ត ដែលទុក ជា ព្រំដែន នៃ សេរីភាព បុគ្គល ចំពោះ ជនដទៃទៀត។ ទស្សនៈ ជាគ្រិះ នៃ ដំណើរ នៃការចេះដឹងខ្មែរ ក្នុង វិវឌ្ឍន៍ ជា ធម្មជាតិ របស់ ជនខ្មែរ និង សង្គមខ្មែរ។

[15] សមតាធម្មជាតិ=Equilibre de la nature។
[16] តួអង្គ= Sujet (ou Etre)។ តួអង្គនៃធម្មជាតិ : Sujet de la nature។

## ២. ដំណើរ នៃ ការចេះដឹងខ្មែរ

- **មានបន្ត** -

ថ្ងៃទី ២៥ ធ្នូ ឆ្នាំ ២០១៤

ឧប សៅ សង្ហា